ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
១៦០ / ១៣-០២-២០១៣
សាលដីកា
លេខ៨១ "ក្រ.វ.ង"
ចុះថ្ងៃទី៣១-១០-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទីម្ភៃមួយ ខែតុលា ឆ្នាំពីរពាន់ដប់បី ដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted]

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ១៦០ ចុះថ្ងៃទី១៣-០២-២០១៣ រវាង:

១-ជនជាប់ចោទឈ្មោះ [redacted] តារិទ្ធ ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ ជាងផ្សារដែក កើតនៅភូមិ[redacted] ។ ទីលំនៅបច្ចុប្បន្នផ្ទះជួលលេខ[redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ[redacted] ពេជ្រ (រ) មានកូន ០១នាក់ ទោសពីមុខគ្មាន ។ (ប្តឹងឧទ្ធរណ៍)

ឃុំខ្លួន ថ្ងៃទី២២-ធ្នូ-២០១១ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៣៨៤ តព្រ ចុះថ្ងៃទី២២-ធ្នូ-២០១១។

២-ជនជាប់ចោទឈ្មោះ[redacted] វណ្ណៈ ហៅ ណាក់ ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ រត់ម៉ូតូឌុប កើតនៅភូមិ[redacted] ។ ទីលំនៅបច្ចុប្បន្នផ្ទះ[redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (រ) មានកូន ០២នាក់ ទោសពីមុខគ្មាន ។

ឃុំខ្លួនថ្ងៃទី២១-មិនា-២០១២ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៤៨៤តព្រ ចុះថ្ងៃទី២១-មិនា-២០១២។

៣-ជនជាប់ចោទឈ្មោះ[redacted] ពិទូ ហៅ តាព ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ ជាងភ្លើង

កើតនៅភូមិ[redacted] ទីលំនៅមិនពិតប្រាកដ ។ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុខគ្មាន ។

ឃុំខ្លួនថ្ងៃទី០៨-០៦-២០១២ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៩៣៤ តព្រ ចុះថ្ងៃទី០៨-០៦-២០១២។

<u>**ជាប់ចោទពីបទ:**</u> លួចរត់ និង ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស

ប្រព្រឹត្តនៅការិយាល័យប្រឆាំងគ្រឿងញៀន សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ ។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៥៦០ , ៥៦១ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ ។

## **ឯរឿងហេតុមានដូចតទៅ**

នៅយប់ថ្ងៃទី ០៦-ធ្នូ-២០១១ ជនជាប់ចោទទាំងបីនាក់ឈ្មោះ [redacted] ភារិទ្ធ , [redacted] ពិទូ, និងឈ្មោះ [redacted] វណ្ណៈ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនយកមកសួរចម្លើយនៅការិយាល័យប្រឆាំងគ្រឿងញៀន ពីបទៈ ជួញដូរគ្រឿងញៀនខុសច្បាប់ ។ លុះដល់វេលាម៉ោង ៨យប់ នាថ្ងៃខែឆ្នាំដដែល ជនជាប់ចោទទាំងបីនាក់បានពិភាក្សាគ្នា និងរៀបគំរោងលួចរត់ចេញពីកន្លែងឃាត់ខ្លួននៅការិយាល័យប្រឆាំងគ្រឿងញៀន ។ ពេលនោះ ដោយជនជាប់ចោទឈ្មោះ [redacted] ពិទូ ហៅ ភាព ជាអ្នកអារចម្រឹងដែក និងគាស់ទ្វារ ។ រីឯជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ភារិទ្ធ ជាអ្នកចាំមើលផ្លូវ ។ បន្ទាប់ពីជនជាប់ចោទទាំងបីនាក់អារចម្រឹកដែក និងគាស់ទ្វារបន្ទប់ឃាត់ខ្លួននៅការិយាល័យប្រឆាំងគ្រឿងញៀនបានសម្រេច ក៏នាំគ្នារត់គេចខ្លួនបាត់អស់តែម្តង ។

## <u>**អំពីលទ្ធផលអង្កេត**</u>

-បានឃើញចម្លើយជនជាប់ចោទឈ្មោះ [redacted] ភារិទ្ធ បានឆ្លើយថា ៖ កាលពីថ្ងៃទី ០៦-ធ្នូ-២០១១ ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួនយកមកសួរចម្លើយ នៅការិយាល័យប្រឆាំងគ្រឿងញៀនជាមួយ ឈ្មោះ [redacted] វណ្ណៈ និង ឈ្មោះ [redacted] ពិទូ ពីបទៈ ជួញដូរគ្រឿងញៀន ។ ខ្លួនមិនបានចូលរួមក្នុងសកម្មភាពអារចម្រឹងដែកជាមួយឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ពិទូ នោះទេ ពីព្រោះពេលនោះខ្លួនឈឺពោះ ដោយបានលេបថ្នាំ ហើយក៏ដេកលក់ទៅ ប៉ុន្តែខ្លួនបានឮសំឡេងអារចម្រឹងដែក តែខ្លួនមិនបានចាប់អារម្មណ៍ថានរណាជាអ្នកអារនោះទេ។ បន្ទាប់មកខ្លួនបានឮសំឡេងឈ្មោះ [redacted] វណ្ណៈ និយាយទូរស័ព្ទថា តើនរណាអារដែករបស់អញបានហើយឬនៅ? ។ ចំពោះការលួចរត់ចេញពីកន្លែងឃាត់ខ្លួន គឺខ្លួនពិតជាបានលួចរត់ចេញជាមួយឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ពិទូ នាថ្ងៃកើតហេតុ វេលាម៉ោងប្រហែល ១០យប់ប្រាកដមែន ។

-បានឃើញចម្លើយជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ បានឆ្លើយថា ៖ កាលពីថ្ងៃទី ០៦-ធ្នូ-២០១១ ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួនយកមកសួរចម្លើយ នៅការិយាល័យប្រឆាំងគ្រឿងញៀនជាមួយ ឈ្មោះ [redacted] ភារិទ្ធ និងឈ្មោះ [redacted] ពិទូ ពីបទៈ ជួញដូរគ្រឿងញៀន ។ ខ្លួនពិតជាបានទូរស័ព្ទទៅប្រពន្ធឈ្មោះ [redacted] ចាន់ ឱ្យយករណាអារដែកមកឱ្យខ្លួនប្រាកដមែន ។ ប៉ុន្តែប្រពន្ធខ្លួនមិនបានយករណាអារដែកនោះមកឱ្យខ្លួនទេ ។ លុះមកដល់ម៉ោង ៨យប់ នាថ្ងៃខែឆ្នាំដដែល ស្រាប់តែឈ្មោះ [redacted] ពិទូ បានយករណាអារដែកដែលបានពីស្រីវាមកអារចម្រឹងដែកតែម្តង ។ ចំពោះសកម្មភាពអារចម្រឹងដែក និង គាស់ទ្វារនោះ គឺខ្លួន ,

ឈ្មោះ [redacted] ភារិទ្ធ និងឈ្មោះ [redacted] ពិទូ បានពិភាក្សាគ្នាជាមុន ដោយឈ្មោះ [redacted] ពិទូ ជាអ្នកអារចម្រឹងដែក និងគាស់ទ្វារ ។ រីឯ ខ្លួននិងឈ្មោះ [redacted] ភារិទ្ធ ជាអ្នកយាមផ្លូវ ។

-បានឃើញចម្លើយជនជាប់ចោទឈ្មោះ [redacted] ពិទូ បានឆ្លើយថា ៖ កាលពីថ្ងៃទី ០៦-ធ្នូ-២០១១ ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួនយកមកសួរចម្លើយ នៅការិយាល័យប្រឆាំងគ្រឿងញៀនជាមួយ ឈ្មោះ [redacted] ភារិទ្ធ និងឈ្មោះ [redacted] វណ្ណៈ ពីបទៈ ជួញដូរគ្រឿងញៀន ។ លុះមកដល់ម៉ោង ៨យប់ នាថ្ងៃខែឆ្នាំដដែល ឈ្មោះ [redacted] វណ្ណៈ បានយករណារអារដែកដែលបានមកពីស្រីរបស់វាឈ្មោះកំពីងរាជ យកមកអារចម្រឹងដែក និងជាអ្នកគាស់នៅកន្លែងឃាត់ខ្លួនក្នុងការិយាល័យប្រឆាំងគ្រឿងញៀន ។ រីឯ ខ្លួន និងឈ្មោះ [redacted] ភារិទ្ធ ជាអ្នកចាំមើលផ្លូវ ។ រហូតដល់ម៉ោងប្រហែល ១០យប់ ខ្លួនក៏បានរត់គេចខ្លួនចេញពីការិយាល័យប្រឆាំងគ្រឿងញៀន បន្ទាប់មកខ្លួនបានទៅរស់នៅឯខេត្តពោធិសាត់ ។ លុះមកដល់ថ្ងៃទី ០៦-មិថុនា-២០១២ ខណៈពេលខ្លួនមកចូលរួមពិធីបុណ្យសពម្ដាយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង ។ ខ្លួនបានដឹងថា មានដីកាបង្គាប់ឱ្យចាប់ខ្លួនតែខ្លួនមិនហ៊ានចូលមកតុលាការពីព្រោះខ្លាចគេចាប់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៧ "ប" ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចដូចខាងក្រោម :

១-ផ្ដន្ទាទោសលើ:

ក-ឈ្មោះ [redacted] ភារិទ្ធ ភេទប្រុស អាយុ ២៧ឆ្នាំ ។

ខ-ឈ្មោះ [redacted] វណ្ណៈ ហៅ ណាក់ ភេទប្រុស អាយុ ៣២ឆ្នាំ ។

គ-ឈ្មោះ [redacted] ពិទូ ហៅ ភាព ភេទប្រុស អាយុ ៣១ឆ្នាំ ។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៥.000.000 (ប្រាំលាន) រៀល ។

ពីបទៈ លួចរត់ និងធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅការិយាល័យប្រឆាំងគ្រឿងញៀនសង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ ។

បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្ដន្ទាទោសតាមមាត្រា ៥៦១ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ ។

២-វត្ថុចាប់យក រួមមាន:

ក-ទូរស័ព្ទដៃចាស់ៗបីគ្រឿងខូច ។

ខ-កូនសៀវភៅកត់លេខទូរស័ព្ទមួយក្បាល ។

គ-ម៉ូតូមួយគ្រឿងម៉ាកវីវ៉ាពណ៌ខ្មៅ លេខតួ និងលេខម៉ាស៊ីន BE4CCTH 100922 ពាក់ផ្លាកលេខភ្នំពេញ 1T-9781 បែកស្រទាប់ការពារមួយចំនួន (ម៉ូតូចាស់) ។

ឃ-លុយខ្មែរ ១០000 រៀល (មួយម៉ឺនរៀល) ។

ង-កាបូបដៃ ពណ៌ខ្មៅមួយ សៀវភៅកត់លេខទូរស័ព្ទមួយ អត្តសញ្ញាណប័ណ្ណរបស់ឈ្មោះ [redacted] មួយ និងប័ណ្ណសំគាល់យានយន្តរបស់ឈ្មោះ [redacted] មួយ ។

ត្រូវប្រគល់ឱ្យទៅម្ចាស់ដើមវិញ ។

ច-កូនថង់ប្លាស្ទិកសម្រាប់ច្រកគ្រឿងញៀន ៦កូនថង់ និងក្រដាសអាលុយមីញ៉ូមនៅក្នុងកូនថង់ចំនួន ៥ ។



២២៥

ត្រូវរឹបអូសបំផ្លាញចោល ។

៣-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ភារិន្ទ ,ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ហៅ ណាក់ និង ជនជាប់ចោទឈ្មោះ [redacted] ពិទូ ហៅ ភាព ។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

*បានឃើញបណ្តឹងឧទ្ធរណ៍៤៥៣ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ របស់ ឈ្មោះ [redacted] ភារិន្ទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ២៧ "ប" ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១២ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។*

-បានឃើញ របាយការណ៍របស់សាលាឧទ្ធរណ៍

-បានឃើញ សេចក្តីសន្និដ្ឋានរបស់មហាអយ្យការ

## នាពេលសវនាការ

### ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុ

-ជនជាប់ចោទឈ្មោះ [redacted] ភារិន្ទ បានឆ្លើយថាៈ ខ្លួនប្តឹងឧទ្ធរណ៍នេះ ដោយសារខ្លួនមិនបានប្រព្រឹត្តទេ ព្រោះនៅមុនថ្ងៃកើតហេតុនោះ ពេលខ្លួនកំពុងហូបបាយជាមួយឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ពិទូ ក៏និយាយគ្នាលេងពីរឿងលួចរត់នេះ ។ ខ្លួនពិតជាបានលួចរត់ពីកន្លែងឃុំឃាំងមែន ប៉ុន្តែខ្លួនពុំបានអារចំរឹងដែកទេ ដោយសារយប់នោះខ្លួនឈឺពោះ ខ្លួនបានដេកលក់ ។ ចំណែកឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ពិទូ ជាអ្នកអារចំរឹងដែក ។ នៅពេលនេះខ្លួនសំណូមពរ សូមលោកប្រធានជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានៈ នៅក្នុងរឿងនេះ ជនជាប់ចោទបានឆ្លើយសារភាពថា ពិតជាបានរត់មែន តែមិនបានអារចំរឹងដែកទេ ។ ដូច្នេះតំណាងមហាអយ្យការសូមក្រុមប្រឹក្សា ពិចារណា និង សម្រេចតាមច្បាប់ ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សភាព្រហ្មទណ្ឌ យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ៤៥៣ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ភារិន្ទ ជាជនជាប់ចោទ បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ២៧ "ប" ចុះថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ភារិន្ទ បានឆ្លើយបញ្ជាក់ថា : នៅថ្ងៃកើតហេតុថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១១ ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួនយកទៅសួរចម្លើយ នៅការិយាល័យប្រឆាំងគ្រឿងញៀនជាមួយឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ពិទូ ពីបទ ជួញដូរគ្រឿងញៀន ខ្លួនពិតជាបានលួចរត់ពីកន្លែង

ឃុំឃាំងមែន ប៉ុន្តែខ្លួនពុំបានអារចំរឹងដែកទេ ដោយសារយប់នោះខ្លួនឈឺពោះ ខ្លួនបានដេកលក់ ។ ចំណែកឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ពិទូ ជាអ្នកអារចំរឹងដែក ។ ផ្ទុយទៅវិញ តាមចម្លើយរបស់ឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ពិទូ បានបញ្ជាក់ថា ពួកខ្លួនទាំង៣នាក់ បានពិភាក្សាគ្នាមុនពេលធ្វើសកម្មភាពអារចំរឹងដែក និងគាស់ទ្វារកន្លែងឃុំឃាំង ឈ្មោះ [redacted] ភារិន្ទ ជាអ្នកចាំមើលផ្លូវ ។

៣-មានពិរុទ្ធភាព លើឈ្មោះ [redacted] ភារិន្ទ ពីបទ លួចរត់ និង ធ្វើឲ្យខូចខាតដោយចេតនា មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅការិយាល័យប្រឆាំងគ្រឿងញៀន សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥៦១ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ ។

៤-សំអាងហេតុ និងសេចក្តីសម្រេច នៃសាលក្រមព្រហ្មទណ្ឌលេខ ២៧ "ប" ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវហើយ ។ គប្បីតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**ទនិច្ឆ័យសេចក្ត**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ៤៥៣ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ភារិន្ទ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៧ "ប" ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ភារិន្ទ តាមនីតិវិធី ។

៤-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ។ បើកសិទ្ធិប្តឹងសាទុក្ខ ក្នុងអំឡុងពេល០១ ខែ គិតពីថ្ងៃប្រកាសសាលដីកា ។

*សេចក្តីនេះព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តតាមសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរតាមច្បាប់ ។*

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធាន |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]



៤៥០